ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៤៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសំរួលសមាសភាពគណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហម
- បានឃើញកិច្ចព្រមព្រៀងស្តីពីការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣
- បានឃើញសេចក្តីសម្រេច លេខ ១៣ សសរ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារធានាសន្តិសុខសំរាប់កិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម
- បានឃើញសេចក្តីសម្រេច លេខ ៥៤ សសរ ចុះថ្ងៃទី ០៦ ខែ កញ្ញាឆ្នាំ ២០០៤ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ
- បានឃើញសេចក្តីសម្រេច លេខ ២៦ សសរ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយក ដ្ឋានពន្ធនាគារ
- យោងតាមការចាំបាច់ និងសំណើរបស់គណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ

# ស ម្រេ ច

**ប្រការ ១ :** ត្រូវបានតែងតាំង **ឯកឧត្តម ឧត្តមសេនីយ៍ឯក ហេង ហាក់** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ជំនួស **ឯកឧត្តម ឪច សុន** ដូចបានតែងតាំងក្នុងសេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលសមាសភាព គណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ របស់ រាជរដ្ឋាភិបាល ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានគណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ ប្រធានការិយាល័យរដ្ឋបាល នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ✓

www.pheakdeylaw.com